ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តសៀមរាប

លេខ: ១០១ សាសរ

សៀមរាប.ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥

# ដីកា

## ស្តីពី

## ការធ្វើប្រតិភូកម្មអំណាចការងារនីត្យានុកូលភាព លើឯកសារផ្សេងៗ ជូនដល់ស្រុកសៀមរាប

## អភិបាលខេត្ត

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០៤/០១៣ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងមុខតំណែង អភិបាលខេត្ត-ក្រុង ។

-បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

-បានឃើញប្រកាសលេខ ៧៩១ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤ របស់ក្រសួងមហាផ្ទៃ ស្តីពីរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

-យោងលិខិតលេខ ៤១៩ សជណ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រគល់សិទ្ធិឱ្យអភិបាលខេត្តទាំងពីរចេញដីកាប្រគល់ភារកិច្ចដល់មន្ត្រីរាជការ សំរាប់បំពេញការងារក្នុងរចនាសម្ព័ន្ធថ្មី របស់ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

-តាមការចាំបាច់របស់សាលាខេត្តសៀមរាប ។

## សំរេច

ប្រការ១ : ត្រូវបានធ្វើប្រតិភូកម្មអំណាចការងារនីត្យានុកូលភាព លើឯកសារផ្សេងៗ ជូនដល់ស្រុកសៀមរាបដូចខាងក្រោម :

១- វិញ្ញាបនបត្របញ្ជាក់ការសិក្សា

២-វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាកំរិត ១

៣-វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាកំរិត ២ -

៤- វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាបឋមភូមិ

៥-វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាទុតិយភូមិ

៦-វិញ្ញាបនបត្របញ្ចប់ការសិក្សាថ្នាក់ទី ១២

៧- វិញ្ញាបនបត្រចុះបញ្ជីរភាគរលើតំលៃបន្ថែម

៨- វិញ្ញាបនបត្រប្រកបអាជីវកម្ម

៩- វិញ្ញាបនបត្របណ្ដោះអាសន្នថ្នាក់បរិញ្ញាប័ត្រ

១០- វិញ្ញាបនបត្រ

១១- លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកំរិត ១

១២- សញ្ញាបត្រ មធ្យមសិក្សាកំរិត២ ( បំពេញវិជ្ជា )

១៣- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

១៤- សញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ

១៥- សញ្ញាបត្រមធ្យមសិក្សា

១៦- សញ្ញាបត្រគ្រូបង្រៀនកំរិតឧត្តម

១៧-ព្រឹត្តិប័ត្រលទ្ធផលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

១៨-បរិញ្ញាបត្រ

១៩- បរិញ្ញាបត្ររង

២០- លិខិតបញ្ជាក់ការសិក្សា

២១- អត្តសញ្ញាណប័ណ្ណ

២២- សៀវភៅស្នាក់នៅ

២៣- បណ្ណ័សំគាល់យានយន្ត

២៤- ព្រឹត្តិបត្រពិន្ទុ

២៥- ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកំរិត ២ ចំនេះដឹងទូទៅ

<u>ប្រការ ២</u> : បញ្ជូនតារាងតំលៃដែលធ្លាប់មានកន្លងមក ជូនដល់ស្រុកសៀមរាប ចំពោះតំលៃថ្មី គឺស្រុកត្រូវ ពិភាក្សា ជាមួយមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត និង អង្គភាពពាក់ព័ន្ធសារជាថ្មី រួចរាយការណ៍ជូនអភិបាលខេត្ត ។

<u>ប្រការ ៣</u> : ចំពោះឯកសារផ្សេងទៀត បើស្រុកយល់ឃើញថាចាំបាច់ ស្រុកត្រូវស្នើសុំបន្ថែមទៀត ។

<u>ប្រការ ៤</u> ៖ នាយខុទ្ទកាល័យសាលាខេត្ត ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត ប្រធានអង្គភាពពាក់ព័ន្ធ អភិបាលស្រុកសៀមរាប ត្រូវអនុវត្តតាមដីកានេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**អភិបាលខេត្ត**

ស៊ឹម . សុជិ

***<u>កន្លែងទទួល</u>***

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់
-ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងពាក់ព័ន្ធ

"*<u>សូមគោរពជូនជ្រាប</u>*"

-ដូចប្រការ២. ៤

"*<u>ដើម្បីអនុវត្ត</u>*"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តសៀមរាប

តារាងសម្រង់លិខិតឯកសារផលិតផល
ដែលបានធ្វើនីត្យានុកូលកម្ម និង តម្លៃសេវាកម្មដែលបានប្រមូល

| ល.រ | ខ្ទឹមសារដែលបានធ្វើនីត្យានុកូលភាព | តម្លៃធ្វើនីត្យានុកូលភាព | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ទឹកប្រាក់សរុប | តម្លៃសេវាកម្ម | តម្លៃតែម ប្រិយ៍ | ចំនួនក្រដាស | |
| ១ | វិញ្ញាប័ណ្ណប័ត្របញ្ជាក់ការសិក្សា | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ២ | វិញ្ញាបនប័ត្របណ្ដោះអាសន្ន មធ្យមសិក្សាកំរិត ១ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ៣ | វិញ្ញាបនប័ត្របណ្ដោះអាសន្ន មធ្យមសិក្សាកំរិត ២ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ៤ | វិញ្ញាបនប័ត្របណ្ដោះអាសន្ន មធ្យមសិក្សាបឋមភូមិ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ៥ | វិញ្ញាបនប័ត្របណ្ដោះអាសន្ន មធ្យមសិក្សាទុតិយភូមិ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ៦ | វិញ្ញាប័ណ្ណប័ត្របញ្ជាក់ការសិក្សាថ្នាក់ទី១២ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ៧ | វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម | ១.០០០៛ | ៨០០៛ | ២០០៛ | មួយសន្លឹក | |
| ៨ | វិញ្ញាបនប័ត្រប្រកបអាជីវកម្ម | ១.០០០៛ | ៨០០៛ | ២០០៛ | មួយសន្លឹក | |
| ៩ | វិញ្ញាបនប័ត្រ បណ្ដោះអាសន្ន ថ្នាក់បរិញ្ញាប័ត្រ | ១.០០០៛ | ៨០០៛ | ២០០៛ | មួយសន្លឹក | |
| ១០ | វិញ្ញាបនប័ត្រ | ១.០០០៛ | ៨០០៛ | ២០០៛ | មួយសន្លឹក | |
| ១១ | លិខិតបញ្ជាក់លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាកំរិត១ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ១២ | សញ្ញាប័ត្រមធ្យមសិក្សា កំរិត ២ ( បំពេញវិជ្ជា) | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ១៣ | សញ្ញាប័ត្រមធ្យមសិក្សា ទុតិយភូមិ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |

| | | | | | | |
|---|---|---|---|---|---|---|
| ១៤ | សញ្ញាប័ត្រមធ្យមសិក្សា គរុកោសល្យ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ១៥ | សញ្ញាប័ត្រមធ្យមសិក្សា | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ១៦ | សញ្ញាប័ត្រគ្រូបង្រៀនកំរិតឧត្តម | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ១៧ | ព្រឹត្តិប័ត្រលទ្ធផល សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ១៨ | បរិញ្ញាប័ត្រ | ១.០០០៛ | ៨០០៛ | ២០០៛ | មួយសន្លឹក | |
| ១៩ | បរិញ្ញាប័ត្ររង | ១.០០០៛ | ៨០០៛ | ២០០៛ | មួយសន្លឹក | |
| ២០ | លិខិតបញ្ជាក់ការសិក្សា | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ២១ | អត្តសញ្ញាណប័ណ្ណ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ២២ | សៀវភៅស្នាក់នៅ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ២៣ | ប័ណ្ណសំគាល់យានយន្ត | ១.០០០៛ | ៨០០៛ | ២០០៛ | មួយសន្លឹក | |
| ២៤ | ព្រឹត្តិប័ត្រពិន្ទុ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |
| ២៥ | ពាក្យសុំបញ្ជាក់សញ្ញាប័ត្រមធ្យមសិក្សាកំរិត២ចំណេះដឹងទូទៅ | ៧០០៛ | ៥០០៛ | ២០០៛ | មួយសន្លឹក | |

បានឃើញ និង ឯកភាព

អភិបាលខេត្ត

លីម - សុភ

សៀមរាប ថ្ងៃទី០៤ ខែ[illegible]ឆ្នាំ២០០៥

នាយខុទ្ទកាល័យ

ប៊ុន.ចារឬទ្ធិ